ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

លេខៈ ៦៣៨ គ.ជ.ប. ស.ស.រ

# សេចក្ដីសម្រេច

## ស្ដីពី

## ការបង្កើតក្រុមប្រតិកម្មព័ត៌មានរបស់ គ.ជ.ប

## គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៥/០០២ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៥/៣២៧ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៥ ស្ដីពីការតែងតាំងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១៥/៦៤៨ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៥ ស្ដីពីលក្ខន្តិកៈដោយឡែកនៃក្របខណ្ឌមន្ត្រីរាជការ នៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញសេចក្ដីសម្រេចលេខ ០៩៥ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៧ ស្ដីពីការប្រកាសឱ្យប្រើបទបញ្ជាផ្ទៃក្នុងរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- យោងតម្រូវការចាំបាច់ ។

## សម្រេច

**ប្រការ ១.-**

ត្រូវបានបង្កើតក្រុមប្រតិកម្មព័ត៌មានដើម្បីជួយការងារប្រធាន គ.ជ.ប និង គ.ជ.ប ។ ក្រុមប្រតិកម្មព័ត៌មាន ជាសេនាធិការរបស់ប្រធាន គ.ជ.ប សម្រាប់ទប់ស្កាត់ និងវាយបករាល់ចំណុចអវិជ្ជមាន ។

**ប្រការ ២.-**

ក្រុមប្រតិកម្មព័ត៌មាន មានសមាសភាពដូចតទៅៈ

| | | | |
|---|---|---|---|
| ១. ឯកឧត្តម | **សោម សូរីដា** | អគ្គលេខាធិការរង គ.ជ.ប | ជាប្រធាន |
| ២. ឯកឧត្តម | **ឡេង សុជា** | ទីប្រឹក្សាឯកឧត្តមប្រធាន គ.ជ.ប | ជាអនុប្រធាន |

| | | | |
|---|---|---|---|
| ៣. ឯកឧត្តម | **ខៀវ ចំរើន** | ទីប្រឹក្សាឯកឧត្តមប្រធាន គ.ជ.ប និងជាអនុប្រធាននាយកដ្ឋានគ្រប់គ្រងទិន្នន័យ និងបញ្ជីបោះឆ្នោត | ជាសមាជិក |
| ៤. ឯកឧត្តម | **កែវ ផល្លា** | ទីប្រឹក្សា គ.ជ.ប និងជាប្រធាននាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម | ជាសមាជិក |
| ៥. ឯកឧត្តម | **កែ រឹទ្ធិ** | ទីប្រឹក្សាឯកឧត្តមប្រធាន គ.ជ.ប និងជាអនុប្រធាននាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម | ជាសមាជិក |
| ៦. លោក | **ខន កែវមនោ** | ប្រធាននាយកដ្ឋានព័ត៌មាន និងទំនាក់ទំនងសាធារណៈ | ជាសមាជិក |
| ៧. លោក | **តុប ឫទ្ធី** | ប្រធាននាយកដ្ឋានគ្រប់គ្រងទិន្នន័យ និងបញ្ជីបោះឆ្នោត | ជាសមាជិក |

**ប្រការ ៣._**

ក្រុមប្រតិកម្មព័ត៌មាន មានភារកិច្ច និងការទទួលខុសត្រូវ ដូចតទៅ ៖

- ក្រុមប្រតិកម្មព័ត៌មានត្រូវស្ថិតក្រោមការណែនាំ និងបញ្ជាផ្ទាល់របស់ប្រធាន គ.ជ.ប
- ប្រមូលព័ត៌មានពាក់ព័ន្ធនឹងការបោះឆ្នោតពីគ្រប់នាយកដ្ឋានពាក់ព័ន្ធ គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត (គធ.ខប) ឬលេខាធិការដ្ឋានរាជធានី ខេត្តរៀបចំការបោះឆ្នោត (លធ.ខប) ទាំង ២៥
- ប្រមូលព័ត៌មានដែលផ្សព្វផ្សាយតាមសារព័ត៌មានជាសាធារណៈ ដើម្បីធ្វើការវិភាគនូវព័ត៌មានអវិជ្ជមាន បង្ខូចកិត្តិយស គ.ជ.ប ធ្វើឱ្យមានការយល់ច្រឡំ បំភ័ន្តសាធារណៈមតិ ទិសដៅធ្វើឱ្យអាប់ឱន ឬធ្វើឱ្យមហាជនមានការសង្ស័យ ឬមិនទុកចិត្តលើស្ថាប័នរៀបចំការបោះឆ្នោត
- ធ្វើការឆ្លើយបំភ្លឺជាលាយលក្ខណ៍អក្សរ ក្នុងករណីព័ត៌មានពិនិត្យឃើញការផ្សាយព័ត៌មានអវិជ្ជមាន ពាក់ព័ន្ធនឹង គ.ជ.ប ឬដំណើរការរៀបចំការបោះឆ្នោតទាំងមូល
- លើកយោបល់ជូនប្រធាន គ.ជ.ប ជាបន្ទាន់ពីចំណុចអវិជ្ជមានពាក់ព័ន្ធនឹងការបោះឆ្នោត ដែលទទួលបានពីសាធារណជន
- សហការផ្តល់ព័ត៌មានជូនអ្នកនាំពាក្យ គ.ជ.ប
- ក្រុមប្រតិកម្មព័ត៌មាន មានការទទួលខុសត្រូវដាច់ដោយឡែកពីអ្នកនាំពាក្យ គ.ជ.ប
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលប្រធាន គ.ជ.ប ប្រគល់ជូន ។

**ប្រការ ៤._**

របៀបរបបបំពេញការងាររបស់ក្រុមប្រតិកម្មព័ត៌មាន ៖

- បំពេញការងារដោយមិនគិតម៉ោងពេល និងថ្ងៃឈប់សម្រាកឡើយ

- ត្រូវជួបប្រជុំពិភាក្សាគ្នាក្នុងរយៈពេលខ្លី យ៉ាងយូរ ១៥នាទី ជារៀងរាល់ថ្ងៃ នៅបន្ទប់របស់ប្រធានក្រុម ដើម្បីផ្លាស់ប្តូរព័ត៌មាន និងស្តាប់របាយការណ៍ប្រចាំថ្ងៃរបស់មន្ត្រីជំនួយការ
- ត្រូវសរុបរបាយការណ៍សង្ខេប និងវាយតម្លៃលើហេតុការណ៍កើតឡើង ជូនប្រធាន គ.ជ.ប
- លើកយោបល់ចាត់វិធានការទប់ស្កាត់ និងបង្ការនូវព័ត៌មានអវិជ្ជមាន ជូនប្រធាន គ.ជ.ប
- ត្រូវវាយការណ៍ពីព័ត៌មានអវិជ្ជមានពាក់ព័ន្ធនឹងការបោះឆ្នោតផ្ទាល់មាត់ ជូនប្រធាន គ.ជ.ប
- ត្រូវចូលរួមគ្រប់សន្និសីទសារព័ត៌មានរបស់ភាគីពាក់ព័ន្ធ ។

**ប្រការ ៥._**

ដើម្បីជំរុញការងារឱ្យក្រុមប្រតិកម្មព័ត៌មាន មានប្រសិទ្ធភាព និងរហ័សទាន់សភាពការណ៍ ក្រុមនេះ ត្រូវមានក្រុមជំនួយការដែលជាមន្ត្រីទាំងអស់បម្រើការងារនៅនាយកដ្ឋានព័ត៌មាន និងទំនាក់ទំនងសាធារណៈ និងមន្ត្រីមួយចំនួនបម្រើការងារនៅនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម សម្រាប់ជួយការងារ និងត្រូវមានថវិកាសម្រាប់បំពេញការងារ ។

**ប្រការ ៦._**

ក្រុមប្រតិកម្មព័ត៌មានត្រូវមានថវិកាសម្រាប់បេសកកម្ម និងសម្ភារតម្រូវការចាំបាច់មួយចំនួន។

**ប្រការ ៧._**

ក្រុមជំនួយការមានភារកិច្ច ដូចខាងក្រោម ៖

- ប្រមូលឯកសារពីនាយកដ្ឋានពាក់ព័ន្ធ តាមការណែនាំពីក្រុមប្រតិកម្មព័ត៌មាន
- ប្រមូលព័ត៌មានពី គជ.ខប ទាំង ២៥ តាមគ្រប់មធ្យោបាយ ដើម្បីឱ្យទាន់សភាពការ
- ធ្វើការកត់ត្រា និងធ្វើរបាយការណ៍ជាលាយលក្ខណ៍អក្សរសម្រាប់ក្រុមប្រតិកម្មព័ត៌មាន
- សរសេរសេចក្តីព្រាង អត្ថបទបំភ្លឺ និងវាយអត្ថបទតាមបញ្ជាពីក្រុមប្រតិកម្មព័ត៌មាន
- បំពេញភារកិច្ចផ្សេងៗទៀត ដែលក្រុមប្រតិកម្មព័ត៌មានប្រគល់ឱ្យ ។

**ប្រការ ៨._**

ក្រុមប្រតិកម្មព័ត៌មាន មានសិទ្ធិប្រើត្រាអគ្គលេខាធិការ គ.ជ.ប សម្រាប់វាយត្រាលើលិខិតបំភ្លឺ ឬលិខិតឆ្លើយតបដើម្បីផ្សព្វផ្សាយជាសាធារណៈ ។

**ប្រការ ៩._**

នាយកដ្ឋានទាំងអស់ដែលស្ថិតក្នុងអគ្គលេខាធិការដ្ឋាន គ.ជ.ប គជ.ខប/លជ.ខប ទាំង ២៥ រាជធានី ខេត្ត ត្រូវផ្តល់ព័ត៌មានឱ្យបានឆាប់រហ័សតាមដែលអាចធ្វើទៅបាន ក្នុងករណីមានការសាកសួរ ឬស្នើសុំពីក្រុមប្រតិកម្មព័ត៌មាន ។

**ប្រការ ១០._**

សេចក្ដីសម្រេចទាំងឡាយណាដែលផ្ទុយនឹងសេចក្ដីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ១១._**

អគ្គលេខាធិការ គ.ជ.ប នាយកដ្ឋាននៃអគ្គលេខាធិការដ្ឋាន គ.ជ.ប គធ.ខប លធ.ខប ទាំង ២៥ រាជធានី ខេត្ត និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសម្រេចនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ថ្ងៃច័ន្ទ ១រោច ខែមិគសិរ ឆ្នាំរកា ព.ស ២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី 06 ខែ ១១ គ.ស ២០១៧
**ជ. គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។**
**ប្រធាន**

ស៊ិក ប៊ុនហុក